រដ្ឋ MAINE

តុលាការមណ្ឌល
ទីតាំង៖ ______________________
សំណុំរឿងលេខ៖ _______________

រវាង

_____________________________ ដើមបណ្តឹង

_____________________________ ដើមបណ្តឹង

**បណ្តឹងរួមគ្មានវិវាទ**
**សុំការកំណត់មុនកំណើតនូវ**
**ភាពជាឪពុកម្តាយ**

19-A M.R.S. §§ 1921-1938, 1652, 1653, 1851

និង

_____________________________ ចុងចម្លើយ

_____________________________ សហព័ទ្ធរបស់ចុងចម្លើយ (ប្រសិនបើរៀបការរួច)

នៅពេលនេះ ដើមបណ្តឹងបានមករួមគ្នាជាមួយចុងចម្លើយ និងចាប់ផ្តើមបណ្តឹងនេះ ដើម្បីកំណត់ភាពជាឪពុកម្តាយ និងសិទ្ធិ និងទំនួលខុសត្រូវរបស់ឪពុកម្តាយចំពោះកូនជាអនីតិជន អនុលោមទៅតាមច្បាប់ស្តីពីភាពជាឪពុកម្តាយរដ្ឋ Maine 19-A M.R.S.§§1931-1938 និងធ្វើសេចក្តីថ្លែងដូចខាងក្រោម៖

1. ដើមបណ្តឹងគឺជាអនាគតឪពុក/ម្តាយរបស់កូន ដែលនឹងកើតនៅថ្ងៃទី_____________________។

2. ចុងចម្លើយគឺជាអ្នកពពោះកូនជាអនីតិជន។

3. ☐ចុងចម្លើយបានរៀបការរួច ហើយសហព័ទ្ធរបស់នាង________________បានចូលរួមជាភាគីម្ខាងនៃរឿងក្តីនេះ។ ឬ

☐ចុងចម្លើយមិនទាន់រៀបការ។

4. ដើមបណ្តឹងស្នាក់នៅ *(ទីក្រុង)* _____________________ *(ខោនធី)* ________________ *(រដ្ឋ)*_____________។

5. ចុងចម្លើយស្នាក់នៅ *(ទីក្រុង)* __________________ *(ខោនធី)* _________ *(រដ្ឋ)*_____________។



សម្រាប់តែការយោងប៉ុណ្ណោះ

6. រដ្ឋ Maine មានយុត្តាធិការនៅក្នុងរឿងក្តីនេះ ព្រោះភាគីទាំងអស់នៃបណ្តឹងនេះយល់ព្រមទទួលយកយុត្តាធិការរបស់រដ្ឋនេះ ហើយភាគីមួយយ៉ាងតិចស្នាក់នៅក្នុងរដ្ឋនេះ។

7. ដើមបណ្តឹង និងចុងចម្លើយបានចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរមួយស្តីពីការពពោះ អនុលោមតាម 19-A M.R.S.§1932។

8. អនុលោមទៅតាមកិច្ចព្រមព្រៀងពពោះ ចុងចម្លើយបានយល់ព្រមពពោះតាមមធ្យោបាយបង្កកំណើតតាមវិធីវេជ្ជសាស្ត្រ ហើយនាង (ព្រមទាំងសហព័ទ្ធរបស់នាង ប្រសិនបើនាងរៀបការរួច) បានយល់ព្រមថាខ្លួនមិនមានសិទ្ធិ និងករណីយកិច្ចជាឪពុក/ម្តាយរបស់កូនដែលចាប់កំណើតតាមរយៈការបង្កកំណើតតាមវិធីវេជ្ជសាស្ត្រឡើយ។

9. ដើមបណ្តឹងបានយល់ព្រមធ្វើជាឪពុក/ម្តាយផ្តាច់មុខរបស់កូនដែលកើតមក និងបានយល់ព្រមទទួលយកសិទ្ធិ និងទំនួលខុសត្រូវរបស់ឪពុកម្តាយទាំងអស់ទៅលើកូនដែលកើតមក ភ្លាមៗក្រោយកំណើតកូន។

10. ដើមបណ្តឹង និងចុងចម្លើយប្រកាសថា កិច្ចព្រមព្រៀងពពោះរបស់ខ្លួនអនុលោមទាំងស្រុងតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់ទាំងអស់ដូចខាងក្រោម។

A. ☐កិច្ចព្រមព្រៀងពពោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានចុះហត្ថលេខាដោយភាគីទាំងអស់។

B. ☐កិច្ចព្រមព្រៀងនេះត្រូវការពេលវេលាមិនច្រើនជាងមួយឆ្នាំដើម្បីសម្រេចការមានផ្ទៃពោះ។

C. ☐ភាគីមួយយ៉ាងតិចនៃកិច្ចព្រមព្រៀងនេះគឺជានិវាសជនស្របច្បាប់នៃរដ្ឋនេះ។

D. ☐កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាមុនពេលផ្ទេរអំប្រីយ៉ុង។

E. ☐អ្នកពពោះមានអាយុ 21 ឆ្នាំ ឬច្រើនជាងនេះ។

F. ☐អ្នកពពោះធ្លាប់សម្រាលកូនយ៉ាងតិចម្នាក់កាលពីមុន។

G. ☐អ្នកពពោះមិនបានផ្តល់កាម៉េតសម្រាប់ការប្រើប្រាស់នៅក្នុងការមានផ្ទៃពោះរបស់នាងឡើយ។ ឬ
☐អ្នកពពោះមិនបានផ្តល់កាម៉េតសម្រាប់ការប្រើប្រាស់នៅក្នុងការមានផ្ទៃពោះរបស់នាង ប៉ុន្តែបានចុះកិច្ចព្រមព្រៀងពពោះជាមួយសមាជិកគ្រួសារម្នាក់។

H. ☐កិច្ចព្រមព្រៀងចែងថា អ្នកពពោះមានសិទ្ធិប្រើសេវាកម្មរបស់អ្នកផ្តល់សេវាថែទាំសុខភាពតាមការជ្រើសរើសរបស់នាង ដើម្បីថែទាំនាងក្នុងអំឡុងពេលមានផ្ទៃពោះ។

I. ☐អ្នកពពោះបានបំពេញការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ ដែលរួមមានការវាយតម្លៃសុខភាពផ្លូវចិត្ត និងបានផ្តល់កំណត់ត្រាទាក់ទងនឹងការវាយតម្លៃដល់អនាគតឪពុក/ម្តាយ។

J. ☐អនាគតឪពុក/ម្តាយបានបំពេញការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ ដែលរួមមានការវាយតម្លៃសុខភាពផ្លូវចិត្ត និងបានផ្តល់កំណត់ត្រាទាក់ទងនឹងការវាយតម្លៃដល់អ្នកពពោះ។

K. ☐អ្នកពពោះមានភាពជាតំណាងឯករាជ្យស្របច្បាប់តាមការជ្រើសរើសរបស់នាង និងដែលត្រូវបានទូទាត់ថ្លៃដោយអនាគតឪពុក/ម្តាយក្នុងរាល់បញ្ហាដែលទាក់ទងនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងពពោះ និងត្រូវបានប្រាប់អំពីផលវិបាកផ្លូវច្បាប់នៃកិច្ចព្រមព្រៀងពពោះនេះ។

L. ☐មេធាវីដែលតំណាងឲ្យអ្នកពពោះបានបំពេញសេចក្តីប្រកាសដែលត្រូវបានភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងពពោះនេះ ដែលថ្លែងថា កិច្ចព្រមព្រៀងនេះបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់នៃច្បាប់ស្តីពីភាពជាឪពុកម្តាយនៃរដ្ឋ Maine។

M. ☐អនាគតឪពុក/ម្តាយមានភាពជាតំណាងឯករាជ្យស្របច្បាប់ក្នុងរាល់បញ្ហាដែលទាក់ទងនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងពពោះ។

N. ☐មេធាវីដែលតំណាងឲ្យអនាគតឪពុក/ម្តាយបានបំពេញសេចក្តីប្រកាសដែលត្រូវបានភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងពពោះនេះ ដែលថ្លែងថា កិច្ចព្រមព្រៀងនេះបំពេញតាមលក្ខខណ្ឌតម្រូវទាំងអស់នៃច្បាប់ស្តីពីភាពជាឪពុកម្តាយនៃរដ្ឋ Maine។

O. ☐កិច្ចព្រមព្រៀងនេះចែងយ៉ាងច្បាស់លាស់ថា អ្នកពពោះត្រូវធ្វើការបង្កកំណើតតាមវិធីវេជ្ជសាស្ត្រ និងព្យាយាមបង្កើតកូនដែលត្រូវបានបង្កកំណើត។

P. ☐កិច្ចព្រមព្រៀងនេះចែងយ៉ាងច្បាស់លាស់ថា អ្នកពពោះមិនមានសិទ្ធិទាមទារភាពជាឪពុកម្តាយរបស់កូនដែលកើតមកឡើយ ហើយអ្នកពពោះទទួលស្គាល់ភាពជាឪពុកម្តាយផ្តាច់មុខរបស់អនាគតឪពុក/ម្តាយលើកូនដែលកើតមកទាំងអស់ ភ្លាមៗបន្ទាប់កំណត់កូន។

Q. ☐អ្នកពពោះបានរៀបការរួច។ កិច្ចព្រមព្រៀងពពោះនេះត្រូវបានចុះហត្ថលេខាដោយសហព័ទ្ធរបស់អ្នកពពោះ សហព័ទ្ធយល់ព្រមគោរពតាមកាតព្វកិច្ចដែលកំណត់ទៅលើអ្នកពពោះដោយលក្ខខណ្ឌនៃកិច្ចព្រមព្រៀងពពោះពរ សហព័ទ្ធទទួលស្គាល់ថាមិនមានសិទ្ធិទាមទារភាពជាឪពុកម្តាយរបស់កូនដែលកើតមកឡើយ និង

សម្រាប់គោលបំណងព័ត៌មានតែប៉ុណ្ណោះ

ទទួលស្គាល់ភាពជាឪពុកម្តាយផ្តាច់មុខរបស់អនាគតឪពុក/ម្តាយលើកូនដែលកើតមកទាំងអស់ ភ្លាមៗ បន្ទាប់កំណើតកូន។ ឬ ☐អ្នកពពោះមិនទាន់រៀបការរួច។

R. ☐កិច្ចព្រមព្រៀងនេះចែងថា អនាគតឪពុក/ម្តាយគឺជាឪពុក/ម្តាយផ្តាច់មុខលើកូនដែលកើតមកទាំងអស់ ភ្លាមៗក្រោយកំណើតកូន ដោយមិនគិតថាតើដីកាតុលាការត្រូវបានចេញនៅពេលកើតឬអត់ឡើយ ថា អនាគតឪពុកម្តាយយល់ព្រមទទួលយកសិទ្ធិ និងទំនួលខុសត្រូវរបស់ឪពុកម្តាយទាំងអស់លើកូនដែល កើតមកទាំងអស់ ភ្លាមៗក្រោយកំណើត ដោយមិនគិតពីចំនួន ភេទ ឬស្ថានភាពផ្លូវចិត្ត ឬផ្លូវកាយរបស់កូន និងថា អនាគតឪពុក/ម្តាយទទួលខុសត្រូវលើការឧបត្ថម្ភហិរញ្ញវត្ថុសម្រាប់កូនដែលកើតមកទាំងអស់ភ្លាមៗ ក្រោយកំណើតកូន។

S. ☐អ្នកពពោះបានចុះហត្ថលេខាលើលិខិតទទួលស្គាល់ជាលាយលក្ខណ៍អក្សរថា នាងបានទទួលកិច្ចព្រមព្រៀងពពោះមួយច្បាប់។

ដោយហេតុនេះ អនុលោមទៅតាម 19-A M.R.S. §1934 ដើមបណ្តឹង និងចុងចម្លើយស្នើសុំដីការួមគ្នា៖

☐ដែលកំណត់ខ្លឹមសារនៃសំបុត្រកំណើត ដោយអនុលោមទៅតាមមាតិកា 22 មាត្រា 2761 និងដែលបង្គាប់ ការិយាល័យទិន្នន័យ ស្រាវជ្រាវ និងអត្រានុកូលដ្ឋានឲ្យចាត់តាំងអនាគតឪពុក/ម្តាយជាឪពុក/ម្តាយរបស់កូន

☐ដែលប្រកាសថា អនាគតឪពុក/ម្តាយគឺជាឪពុក/ម្តាយរបស់កូនដែលកើតមក និងដែលបង្គាប់ថា សិទ្ធិ និងទំនួលខុសត្រូវរបស់ឪពុកម្តាយទាំងអស់ត្រូវបានផ្ទេរឲ្យទាំងស្រុងទៅឲ្យអនាគតឪពុក/ម្តាយ ភ្លាមៗក្រោយកំណើតកូន។

☐ដែលបិទកំណត់ត្រាមិនឲ្យសាធារណជនមើល ដើម្បីការពារភាពឯកជនរបស់កូន និងគូភាគី។

☐ជំនួយបន្ថែមទៀត ដែលតុលាការកំណត់ថាចាំបាច់ និងសមស្រប។

កាលបរិច្ឆេទ៖ ______________________ ______________________________

(ហត្ថលេខារបស់ដើមបណ្តឹង)

មេធាវីរបស់ដើមបណ្តឹង៖ ________________ ដើមបណ្តឹង៖

អាសយដ្ឋាន៖ ________________ អាសយដ្ឋាន៖

________________ ______________________________

ទូរសព្ទ៖ ________________ ទូរសព្ទ៖ ______________________________

សម្រាប់ជាព័ត៌មានប៉ុណ្ណោះ

រដ្ឋ MAINE

______________________ ខោនធី

ដើមបណ្តឹងមានឈ្មោះដូចខាងលើ ________________________________ បានបង្ហាញខ្លួនដោយផ្ទាល់ និងបានស្បថថា សេចក្តីថ្លែងការណ៍ខាងលើគឺពិតប្រាកដ។

នៅចំពោះមុខយើង

កាលបរិច្ឆេទ៖ ____________________________ ______________________________________

មេធាវី / សារការី / ក្រឡាបញ្ជីរង

កាលបរិច្ឆេទ៖ ____________________________ ______________________________________

(ហត្ថលេខារបស់ដើមបណ្តឹង)

មេធាវីរបស់ដើមបណ្តឹង៖ ____________________ ដើមបណ្តឹង៖ ______________________________

អាសយដ្ឋាន៖ ______________________ អាសយដ្ឋាន៖ ______________________________

______________________ ______________________________

ទូរសព្ទ៖ ______________________ ទូរសព្ទ៖ ______________________________

រដ្ឋ MAINE

______________________ ខោនធី

ដើមបណ្តឹងមានឈ្មោះដូចខាងលើ ________________________________ បានបង្ហាញខ្លួនដោយផ្ទាល់ និងបានស្បថថា សេចក្តីថ្លែងការណ៍ខាងលើគឺពិតប្រាកដ។

នៅចំពោះមុខយើង

កាលបរិច្ឆេទ៖ ______________________ ______________________________________

មេធាវី /សារការី / ក្រឡាបញ្ជីរង

កាលបរិច្ឆេទ៖ ______________________ ______________________________________

(ហត្ថលេខារបស់ដើមបណ្តឹង)

មេធាវីរបស់ចុងចម្លើយ៖ ____________________ ចុងចម្លើយ៖ ______________________________

អាសយដ្ឋាន៖ ______________________ អាសយដ្ឋាន៖ ______________________________

______________________ ______________________________

ទូរសព្ទ៖ ______________________ ទូរសព្ទ៖ ______________________________

សម្រាប់ព័ត៌មានប៉ុណ្ណោះ

រដ្ឋ MAINE

_______________________ខោនធី

ចុងចម្លើយមានឈ្មោះដូចខាងលើ__________________________________បានបង្ហាញខ្លួនដោយផ្ទាល់ និង បានស្បថថា សេចក្តីថ្លែងការណ៍ខាងលើគឺពិតប្រាកដ។

នៅចំពោះមុខយើង

កាលបរិច្ឆេទ៖______________________________ ________________________________________

មេធាវី / សារការី / ក្រឡាបញ្ជីរង

កាលបរិច្ឆេទ៖ ____________________________ ________________________________________

(ហត្ថលេខារបស់ចុងចម្លើយ)

មេធាវីរបស់ចុងចម្លើយ៖ ____________________ ចុងចម្លើយ៖__________________________________

អាសយដ្ឋាន៖_______________________ អាសយដ្ឋាន៖ ____________________________

_______________________ ____________________________

ទូរសព្ទ៖ _______________________ ទូរសព្ទ៖ ____________________________

រដ្ឋ MAINE

_______________________ខោនធី

ចុងចម្លើយមានឈ្មោះដូចខាងលើ__________________________________បានបង្ហាញខ្លួនដោយផ្ទាល់ និង បានស្បថថា សេចក្តីថ្លែងការណ៍ខាងលើគឺពិតប្រាកដ។

នៅចំពោះមុខយើង

កាលបរិច្ឆេទ៖________________________ ________________________________________

មេធាវី / សារការី / ក្រឡាបញ្ជីរង